# សហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ: ០៧២/១៤ ស.ខ.ក.ក.

# សេចក្តីអំពាវនាវ

ដើម្បីឆ្លើយតបនឹងការមើលងាយប្រជាជាតិខ្មែរ និងការបំភ្លៃប្រវត្តិសាស្ត្រខ្មែរដោយចេតនារបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម យើងខ្ញុំព្រះករុណា យើងខ្ញុំ សូមលំឱនកាយអំពាវនាវព្រះករុណាព្រះគុណម្ចាស់គ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ ព្រះមេត្តានិងមេត្តារួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដោយមិនប្រកាន់និន្នាការនយោបាយឬសាសនា ឈប់ប្រើប្រាស់ទំនិញយួន និងសេវាកម្មផ្សេងៗរបស់យួនចាប់ពីពេលនេះតទៅ។

ការសាមគ្គីគ្នាដោយមិនប្រើប្រាស់ទំនិញ និងសេវាកម្មផ្សេងៗរបស់យួន គឺជាការឆ្លើយតបដោយសេចក្តីថ្លៃថ្នូរនៃប្រជាជាតិខ្មែរចំពោះអាកប្បកិរិយាដ៏គឃ្លើននៃរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានមើលងាយប្រជាពលរដ្ឋខ្មែរ និងបំភ្លៃប្រវត្តិសាស្ត្រខ្មែរដោយឥតអៀនខ្មាស់។

ការរួបរួមសាមគ្គីគ្នានៃប្រជាជាតិខ្មែរធ្វើពហិការមិនប្រើប្រាស់ទំនិញនិងសេវាកម្មផ្សេងៗរបស់យួននាពេលនេះ គឺជាសារមួយប្រាប់រដ្ឋាភិបាលវៀតណាមឲ្យបញ្ឈប់ការតាំងខ្លួនជាថៅហ្វាយនាយមកលើកម្ពុជា ជាបន្តទៀត។ ព្រោះពេលនេះ ប្រជាពលរដ្ឋខ្មែរត្រូវការរស់នៅដោយសុខសន្តិភាព ឯករាជ្យម្ចាស់ការ និង ទំនាក់ទំនងល្អជាមួយប្រទេសជិតខាងដោយស្មើភាព គោរពគ្នាទៅវិញទៅមក ក្នុងលក្ខណៈឯករាជ្យនិងអធិបតេយ្យពេញលេញ។

ការចូលរួមមិនប្រើប្រាស់ទំនិញនិងសេវាកម្មរបស់យួន ដូចជា មី កាហ្វេ បន្លែ សាច់ គ្រឿងឧបភោគបរិភោគ និងសេវាកម្មផ្សេងៗ ដូចជា ទូរស័ព្ទ(០៩៧) យន្តហោះ មន្ទីរពេទ្យ ។ល។ គឺជាការចូលរួមការពារកិត្តយសជាតិ និង ការពារប្រវត្តិសាស្ត្រខ្មែរយ៉ាងពិតប្រាកដ។ ជាមួយគ្នានេះក៏ជាការចូលរួមជួយលើកកម្ពស់ទំនិញនិងសេវាកម្មផ្សេងៗរបស់ជាតិខ្មែរយើងផងដែរ។

សហគមន៍ខ្មែរកម្ពុជាក្រោម និង សម្ព័ន្ធយុវជនខ្មែរ ដើម្បីប្រជាធិបតេយ្យ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនរួមឈាមទាំងអស់ ដែលបានចូលរួមឈប់ប្រើប្រាស់ទំនិញនិងសេវាកម្មផ្សេងៗរបស់យួន។

**ជយោ! ព្រះរាជាណាចក្រកម្ពុជា**
**រួមសាមគ្គីគ្នាឈប់ប្រើប្រាស់ទំនិញនិងសេវាកម្មយួន!**

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលា ព.ស.២៥៥៨ គ.ស.២០១៤

**ថាច់ សេដ្ឋា**

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម


ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខ: (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity